EAC

# អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី២

## លើឯកសារអាជ្ញាប័ណ្ណរួមលេខ ១៧៨ ឯអ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧

## របស់លោក ពេជ្រ សុភាព ធ្វើសេវាកម្មអគ្គិសនីនៅទីរួមស្រុកសំរោង ខេត្តតាកែវ

## សម្រាប់ពង្រីកតំបន់ចែកចាយអគ្គិសនី

## DECISION ON SECOND REVISION

OF THE CONSOLIDATED LICENSE DOCUMENT N°178LD DATED AUGUST 31. 2007

FOR MR. PECH SOPHEAP FOR PROVIDING ELECTRICITY SERVICES

AT SAMRONG DISTRICT TOWN, TAKEO PROVINCE

FOR EXTENDING DISTRIBUTION AREA

ថ្ងៃទី ខែ ឆ្នាំ២០១០

, 2010

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ : -១០ អអក

# សេចក្តីសម្រេចកែសម្រួលលើកទី២
# លើឯកសារអាជ្ញាប័ណ្ណរួមលេខ ១៧៨ ឯអ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧
# សម្រាប់លោក ពេជ្រ សុភាព

# DECISION ON SECOND REVISION
# To the License Document N° 178 LD dated August 31, 2007
# For MR. PECH SOPHEAP

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03, dated 02/02/2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ១៧៨ឯអ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧

- In accordance with License Documents Nº 178 LD dated August 31, 2007.

-យោងពាក្យស្នើសុំពង្រីកតំបន់ចែកចាយរបស់លោក ពេជ្រ សុភាព ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩

- In accordance with the application for extending distribution area of Mr. PECH SOPHEAP dated October 26, 2009.

-យោងរបាយការណ៍របស់នាយកដ្ឋានបញ្ញត្តិកម្មអគ្គិសនី ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩

-Referred to Report of Regulation Department dated December 01, 2009.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ២០០ ដល់ថ្ងៃទី ខែ ឆ្នាំ២០០៩

- In accordance with the consultation with concerned parties and public, made from , 2009 to , 2009

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី នៅថ្ងៃទី ខែ ឆ្នាំ២០០៩

-In accordance with the decision of Electricity Authority of Cambodia's Session Nº , dated , 2009

## សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១** | **Article 1** |
| កែសម្រួលអាជ្ញាប័ណ្ណលេខ ១៧៨ អ ដែលបានផ្តល់ឱ្យលោក ពេជ្រ សុភាព សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅទីរួមស្រុកសំរោង ខេត្តតាកែវ ដោយអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ដូចមានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១កែសម្រួលថ្មី ។ | To revise the License Nº 178 L granted to Mr. PECH SOPHEAP for providing electricity services at Samrong District town, Takeo Province by extending distribution area its existing areas as show in the map in new revised schedule1. |
| **ប្រការ២** | **Article 2** |
| ឧបសម្ព័ន្ធទី១ ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ១៧៨ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។ | The Schedule 1 of the license document Nº 178 LD shall be replaced by new Schedule1 attached here with. |
| **ប្រការ៣** | **Article 3** |
| សេចក្តីសម្រេចនេះនិងឧបសម្ព័ន្ធកែសម្រួលថ្មីនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ១៧៨ ឯអ ។ | This decision and attached revised schedule shall be considered as a part of the license documents Nº 178 LD. |
| **ប្រការ៤** | **Article 4** |
| ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ១៧៨ឯអ និងខ្លឹមសារដែលបានកែសម្រួលរួចហើយ ត្រូវស្ថិតនៅជាធរមានដដែល ។ | The other contents and conditions of the license document Nº 178 LD with its revisions shall remain in force. |
| **ប្រការ៥** | **Article 5** |
| សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | The decision shall come into force from the date of signing. |
| **ប្រការ៦** | **Article 6** |
| អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ១៧៨ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ១៧៨ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | The licensee shall send this decision to deposit additionally at the places, where the license document Nº 178 LD has been deposited in order that the deposited license document Nº 178 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១០

Phnom Penh, , 2010

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF EAC

# ឧបសម្ព័ន្ធទី១
# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី នាថ្ងៃទី ខែ ឆ្នាំ២០១០

## SCHEDULE 1

### AUTHORIZED DISTRIBUTION AREAS

### AS AMMENDED IN SESSION OF EAC Nº DATED , 2010

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យលោក ពេជ្រ សុភាព ធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនីនៅទីរួមស្រុកសំរោង និងតំបន់ឃុំសំរោង ឃុំសឹង្គ ឃុំស្លា ឃុំជើងគួន និងឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ។ | 1. The authorized distribution Areas, where Mr. Pech Sopheap has the right to provide electricity distribution and supply services at Samrong District town and.Khum Samrong area, Khum Seung, Khum Sla, Khum Cheungkoun and Khum Trea , Samrong District Takeo Province. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ "ផែនទីកំណត់ព្រំប្រទល់លេខ 178 LD- Map-Pech Sopheap-Revision-2- 2010 " ដែលភ្ជាប់មកជាមួយ ។ | 2. The authorized distribution area is determined by " the boundary Maps178 LD- Map-Pech Sopheap-Revision-2- 2010" attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើលោក ពេជ្រ សុភាព មានបំណងស្នើសុំពង្រីកឬបន្ថែមតំបន់ចែកចាយថែមទៀត ពេលនោះលោក ពេជ្រ សុភាព ត្រូវរៀបចំឯកសារចាំបាច់នានាដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការកំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យពង្រីក ឬបន្ថែមតំបន់ចែក–ចាយណាមួយ ឧបសម័ន្ធទី១នេះត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្ដីសម្រេចឱ្យពង្រីកបន្ថែមតំបន់ចែកចាយនោះ ។ | 3. Under this license, if Mr. Pech Sopheap intends to request the extension or the additional distribution areas then Mr. Pech Sopheap shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend or to add distribution area, this schedule 1 shall be revised and attached with that authorization. |